ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន
ក្រុមការងារគម្រោង LASED

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤

# សូមគោរពជូន
# ឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

**តាមរយៈ:** អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

**កម្មវត្ថុ** របាយការណ៍ស្តីអំពីលទ្ធផលការងារគម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) សម្រេចបាននៅក្នុងខែកុម្ភៈ ឆ្នាំ២០១៤។

សេចក្តីដូចមានចែងនៅក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូនឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប នូវលទ្ធផលសង្ខេបការអនុវត្តគម្រោង LASED សម្រេចបានដូចខាងក្រោម ៖

## ១. វឌ្ឍនភាពគម្រោង

គម្រោងចុះបញ្ជីដីសរុបបានចំនួន១០.២៧៣,១៣ហិកតា នៅក្នុងឃុំគោលដៅចំនួន០៧ លើផែនការចំនួន ១០.០០០ហិចតា ស្មើនឹង១០២,៧៣% និងបានបែងចែកជូនប្រជាជនចំនួន៣.១៤៨គ្រួសារលើផែនការចំនួន៣០០០គ្រួសារស្មើនឹង១០៤,៩៣% ក្នុងនោះគ្រួសារដែលមានស្ត្រីជាមេគ្រួសារចំនួន១០៧០គ្រួសារ។ រហូតមកទល់ពេលបច្ចុប្បន្នមានប្រជាជនចំនួនគ្រួសារហើយដែលបានចូលតាំងទីលំនៅនៅលើដីសម្បទាន ដែលក្នុងមួយគ្រួសារ ទទួលបានចំណូលពីការងារកសិកម្មនេះលើសពី២០០០ដុល្លារក្នុងមួយឆ្នាំ។

គម្រោងសម្រេចបានលទ្ធផលចំនួន ៩៨% នៃផែនការ កើនលើសខែមុនចំនួន១,៣៧%នៃផែនការ ក្នុងនោះមាន៖ សាងសង់ផ្លូវសម្រេចបានប្រវែង១៩១គម ស្មើនឹង ៩៦,២០% នៃផែនការផ្លូវប្រវែង១៩៨,៥៣គម រៀបចំដីកសិកម្មសរុបបានចំនួន ៦១០ហិចតា កើនជាងខែមុនចំនួន៩ហិចតា និងបញ្ចប់ការរៀបចំដីលំនៅឋាន បានចំនួន១១១ហិកតា ។ គម្រោងបានសាងសង់សាលារៀនបានចំនួន៦ខ្នង ស្មើ៣០បន្ទប់លើផែនការចំនួន០៨ខ្នង ហើយកំពុងសាងសង់សាលារៀន២ខ្នងទៀតសន្ទុះនៃការសាងសង់នោះកើនលើសខែមុនចំនួន២% សាងសង់ប៉ុស្តិ៍សុខភាពរួចចំនួន២ខ្នង នៃផែនការចំនួន ៣ខ្នងសាងសង់មណ្ឌលសហគមន៍ចំនួន២ខ្នង និងកំពុងដំណើរការសាងសង់ប៉ុស្តិ៍សុខភាពមួយខ្នងសម្រេចលទ្ធផលបាន ៧០% កើនលើសខែមុនចំនួន ២០ %។ ចំពោះប៉ុស្តិ៍សុខភាពដែលសាងសង់រួចត្រូវបានដាក់ឱ្យដំណើរការជាសាធារណៈ ដែលមានប្រជាជនសរុបចំនួន៤.៧៦៨នាក់ (ស្រី២៨៥០ នាក់) ក្នុងនោះក៏មានប្រជាជននៅ ក្បែរដីសម្បទានមកពិនិត្យជម្ងឺដែរ។ ដោយឡែកការ បោះបង្គោលកំណត់ព្រំដីសរុបបានចំនួន១៨.៨៨៨បង្គោលដែលកើនលើសខែមុនចំនួន៨៩១ដើម។ក្រៅពីនេះគម្រោងក៏

កំពុងដំណើរការជីកស្រះទឹកមួយទៀតនៅឃុំចំបក់ ចែកសម្ភារៈសាងសង់បង្គន់អនាម័យដល់អ្នកទទួលដីចំនួន៣១១៩គ្រួសារនិងចែកសម្ភារៈសម្រាប់សាងសង់ជម្រកដល់ប្រជាពលរដ្ឋបានចំនួន២៤៩០គ្រួសារ។ សមិទ្ធិផលដែលសម្រេចបានទាំងនេះបានដាក់ឱ្យប្រជាជនប្រើប្រាស់ជាសាធារណៈ ហើយតាមរយៈការគាំទ្រទាំងនេះបានជួយលើកដំកើនជីវភាពរបស់នៅរបស់ប្រជាជនបានមួយកម្រិតធំ។

- ក្រុមការងារគម្រោងថ្នាក់ជាតិចុះពិនិត្យស្ថានភាពអនុវត្ត គម្រោងនៅក្នុងខេត្តគោលដៅទាំងបី ដោយបានពិនិត្យឃើញចំណុចខ្វះខាតនិងផ្តល់អនុសាសន៍ឱ្យក្រុមការងារនៃថ្នាក់ខេត្តទាំងបីធ្វើការកែលំអ។
- ក្រុមការងារថ្នាក់ជាតិសហការជាមួយ និងទីប្រឹក្សាធនាគារពិភពលោករៀបចំឯកសារគតិយុត្តិសម្រាប់គម្រោង LASED បន្តបីឆ្នាំទៀត។
- ក្រុមការងារគម្រោងខេត្តកំពង់ធំសហការជាមួយ មន្ទីរកសិកម្មបានចុះធ្វើការផ្សព្វផ្សាយស្តីពីគោលគំនិតនៃការបង្កើតសហគមន៍អភិវឌ្ឍន៍កសិកម្មនៅទីពោតំបន់១និងតំបន់២ចំនួន០២លើកដែលមានអ្នកចូលរួមសរុបចំនួន ៣០៧នាក់ ក្នុងនោះស្រី ២០៣នាក់។
- ក្រុមការងារគម្រោងថ្នាក់ជាតិ និងខេត្តចុះសម្ភាសន៍ប្រជាពលរដ្ឋដើម្បីស្វែងយល់អំពីកំណើនសេដ្ឋកិច្ច និងផលប៉ះពាល់គម្រោងលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

## ២. ស្ថានភាពហិរញ្ញវត្ថុ

- គម្រោងមានថវិកាសរុបចំនួន ៧០០០.០០០ SDR ស្មើនឹង ១០.៦២៦.៣៦៤,០០ដុល្លារ។គម្រោងទទួលបានថវិកាវិភាជន៍ពីធនាគារពិភពលោកចំនួន១០.២០២.៦០២,១៩ដុល្លារស្មើនឹង៩៦% នៃថវិកាគម្រោងសរុបចំនួន១០.៦២៦.៣៦៤,០០ដុល្លារ។
- គិតពីពេលចាប់ផ្តើមអនុវត្តគម្រោង មកទល់ពេលបច្ចុប្បន្ន គម្រោងចំណាយថវិកាសរុបអស់ចំនួន៩.៩០៧.៦៦៥,១១ដុល្លារ ស្មើនឹង៩៣% នៃថវិកាគម្រោងសរុបចំនួន១០.៦២៦.៣៦៤,០០ដុល្លារ។
- នៅក្នុងខែកុម្ភៈនេះគម្រោងចំណាយថវិកាអស់២២៩.៤៩៦ដុល្លារស្មើនឹង១១%នៃផែនការថវិកាដែលបានគ្រោងក្នុងឆ្នាំ២០១៤ ចំនួន២.១០៩.០៣០,០៨ដុល្លារ និងចំណាយលើសខែមុនចំនួន១៣៦.៥៩៨,៦៣ ដុល្លារដែល ស្មើនឹង៦,៤៨%។
- ចាប់ពីពេលអនុវត្តគម្រោងរហូតទល់ពេលបច្ចុប្បន្ននេះ ដូចនេះធនាគារពិភពលោកត្រូវទម្លាក់ថវិកាឱ្យគម្រោងចំនួន ១.២៥៩.០៧៦,១១ដុល្លារទៀត។

## ៣. បញ្ហាប្រឈមនិងសំណូមពរ

- ការអនុវត្តកិច្ចសន្យារបស់អ្នកម៉ៅការមួយចំនួន មិនបានបញ្ចប់តាមកាលកំណត់នៃកិច្ចសន្យា។ ក្រុមការងារបច្ចេកទេសគម្រោងកំពុងដោះស្រាយបញ្ហានេះ។
- តាមរយៈអ៊ីម៉ែលរបស់ធនាគារពិភពលោកចុះថ្ងៃទី១៤ខែមីនា ឆ្នាំ២០១៤ ធនាគារពិភពលោកនិងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុបានឯកភាពបន្តគម្រោងរយៈពេល០៦ខែទៀត ដោយប្រើថវិកាមានស្រាប់។ ក្រុមការងារគម្រោងនៃស្ថាប័នទាំងពីរ យល់ឃើញថាគម្រោងត្រូវអនុវត្តបន្តក្នុងរយៈពេល៦ខែទៀត ដើម្បីពង្រឹងនិរន្តរភាពក៏ដូចជាត្រៀមការអនុវត្តគម្រោងនៅដំណាក់កាលទី២។

**៤.ផែនការអនុវត្តបន្ត**

- ពង្រឹងសមត្ថភាពសហគមន៍កសិកម្មដែលមានស្រាប់ និងរៀបចំបង្កើនសហគមន៍កសិកម្មនៅតំបន់ដីសម្បទានសង្គមកិច្ច។
- រៀបចុះណែនាំអំពីនីតិវិធីអនុវត្តគម្រោងដល់ ក្រុមការងារគម្រោង នៅខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្តបាត់ដំបង។
- ក្រុមការងារគម្រោងនៃស្ថាប័នទាំងពីរត្រៀមឯកសារនិងសុំគោលការណ៍ជាផ្លូវការ សុំអនុវត្តគម្រោងដំណាក់កាលទី២។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមឯកឧត្តមប្រធានលេខាធិការដ្ឋានគ.ជ.អ.ប មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

**អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននិងជា**
**ប្រធានសម្របសម្រួលគម្រោងLASED**

ជាម ប៉េរ៉ា

**ចំលងជូន**
-គ្រប់នាយកដ្ឋាននៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន
-គ្រប់អង្គភាពនៃលេខាធិការដ្ឋាន គ.ជ.អ.ប

27-03-2014